ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

# អាជ្ញានាមប្រជារាស្ត្រខ្មែរ

លេខ : ៣៣០

## តុលាការកំពូល

ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៩

**សាលដីកា**

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០២ ខែកញ្ញា

លេខ : ២១៥

ឆ្នាំ២០០២ ដោយមានសមាសភាព ដូចតទៅ :

ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០០២

១- ឯកឧត្តម ឃឹម ប៉ុណ្ណ ជាប្រធាន

២- លោក រៀល មួន ជាចៅក្រម

៣- លោក ស៊ិន ឌឹម ជាចៅក្រម

៤- លោក ប៉ែន សារឿន ជាចៅក្រម របាយការណ៍

៥- លោក យស់ សូខឿន ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា ធន់ វណ្ណធឿន

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញាស្តីទី

លោក ប៉ែន ស៊ិន ចៅក្រមរបាយការណ៍(អវត្តមាន)

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ៤៣០ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២១៤ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះឃឹម សន (ជាចុងបណ្តឹងសាទុក្ខ) អាយុ៥៧ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅភូមិសាលាឃុំរំចេក ស្រុកព្រះស្តេច ខេត្តព្រៃវែង ។ឪពុកឈ្មោះវ័ត្ត ឃឹម (ស) ម្តាយឈ្មោះ អ៊ី អ៊ុន (រ) ប្រពន្ធឈ្មោះជួប ម៉ីល មានកូន៨នាក់ ។

និងចុងចម្លើយ ឈ្មោះម៉ុង ឈាត (ម្ចាស់បណ្តឹងសាទុក្ខ) អាយុ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅភូមិសាលា ឃុំរំចេក ស្រុកព្រះស្តេច ខេត្តព្រៃវែង ។ ឪពុកឈ្មោះម៉ុជ ម៉ុង(ស) ម្តាយឈ្មោះហេង យាម (រ) ប្រពន្ធឈ្មោះសុខ សុង មានកូន២នាក់ ។

កម្មវត្ថុបណ្តឹង : ប្តឹងទាមទារសំណងព្យាបាល ។

បានឃើញ បណ្តឹងសាទុក្ខលេខ ២៦៤ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៩ របស់លោក ម៉ុង ឈាត ប្តឹងមិនសុខចិត្ត លើ សេចក្តីសំរេចទាំងមូល នៃសាលដីកា ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ៣៣០ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២០-៩-៩៨របស់ឈ្មោះឃឹម សន ប្តឹងពីឈ្មោះស៊ាង សុខ ដោយហេតុថា កាលពីថ្ងៃទី១៣-១០-៩៨វេលាម៉ោងបួនកន្លះល្ងាចគោរបស់ ស៊ាង សុខបានប្រលែងចោលបណ្តាលឱ្យមានរបួសដល់កូនខ្លួនដែលកំពុងកាន់ខ្សែគោរបស់ខ្លួនឱ្យស៊ីជញ្ជ្រាំងជាយភូមិដោយកូនមានរបួសជាទម្ងន់ ខ្លួនសុំថ្លៃព្យាបាលចំនួនពីរលានរៀល ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ១២៤ ចុះថ្ងៃទី២៤-១២-៩៨ របស់តុលាការខេត្តព្រៃវែង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទចុះថ្ងៃទី០៧-១០-៩៨ ប្តឹងទាមទារប្រាក់ថ្លៃព្យាបាលរបួសកូនទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បង្គាប់ឱ្យចុងចម្លើយឈ្មោះម៉ុង ឈាត សងថ្លៃព្យាបាល និង ជម្ងឺចិត្តជាប្រាក់រៀលចំនួន២,០០០,០០០រៀល(ពីរលានរៀលគត់)ទៅឱ្យជនរងគ្រោះឈ្មោះសន ក៏ ទាមទារលើសពីនេះបដិសេធចោល ។

៣- ទទួលយកសំណូមពររបស់ដើមចោទនាពេលសវនាការសុំឱ្យដាក់គុកបង្ខំលើរូបកាយ ដើម្បីទាមទារសំណងថ្លៃព្យាបាល តាមមាត្រា១២១-១២៧ និង១២៨ នៃច្បាប់ស្តីពីការអនុវត្តសាលក្រមរដ្ឋប្បវេណីដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ៩១ក្រ ចុះថ្ងៃទី០២-៥-៩២ ។

៤- បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីចំនួន៧,០០០រៀល ដើមចោទបានបង់រួចហើយគឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វ៊ីង១,៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀលរង្វាន់អ្នកប្រគល់ដីកាកោះ៥,០០០រៀល កាលបើហួសឧទ្ធរណ៍ឱ្យចុងចម្លើយសងប្រាក់៧,០០០រៀលទៅដើមចោទវិញ និង ឱ្យបង់ពន្ធសមាមាត្រស្មើ $\frac{២,០០០,០០០គុណ១}{១០០}$ = ៨០ភាគរយ ដាក់ចូលថវិការដ្ឋ២០ភាគរយ រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

៥- សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូភាគី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ គិតពីថ្ងៃប្រកាសសាលក្រមនេះទៅ ។

ស្មើនិង១០០ដុល្លា ពន្ធសមាមាត្រនេះ ត្រូវអោយដើមចោទបង់ជាមុនដែរ ទើបបង្គាប់អោយចុងចម្លើយ សងទៅដើមចោទវិញជាក្រោយ ។

៦- សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខដើមចោទសំរេចបើកផ្លូវឧទ្ធរណ៍ក្នុងរយៈពេល ២ខែ គិតពីថ្ងៃប្រកាសសាលក្រម និងកំបាំងមុខចុងចម្លើយ សំរេចបើកផ្លូវប្តឹងទាស់ចំនួន១៥ថ្ងៃ គិតចាប់តាំងពីថ្ងៃទទួលលិខិតសាលក្រមកំបាំងមុខ និងសំរេចបើកផ្លូវឧទ្ធរណ៍ ពីរខែគិតពីថ្ងៃផុតកំណត់ប្តឹងទាស់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍លេខ៤៨៥ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៩៥ របស់ឈ្មោះជាន់ វ៉ារិន ប្តឹងមិនសុខចិត្ត និងសាលក្រមលេខ២៧៤ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញលើសេចក្តីសំរេចទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ២៧៤ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសំរេច ដូចតទៅ :

១- ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៩៥របស់លោកជាន់ វ៉ារិន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុស និងគតិច្បាប់ ។

២- តម្កល់សាលក្រមលេខ៧០ "ក" ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៥ របស់តុលាការក្រុងភ្នំពេញទុកជាបានការពេញទាំងមូល ។

៣- រំលងរួសប្រាក់ប្រដាប់ក្តី ជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍ បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធប្តឹងចំនួន២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០រៀល រង្វាន់អ្នកប្រគល់ដីកាកោះចំនួន៥.០០០រៀល និងចំណាយលើអាជ្ញាធរតុលាការ ចំនួន៥.០០០រៀល ។

៤- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងទាស់ និងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ៣៦៣ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៨ របស់អ្នកស្រីសួន គឹមហេង ប្តឹងមិនសុខចិត្ត និងសាលដីកាលេខ២៧៤ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ នៃសេចក្តីសំរេចទាំងមូល ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តី សន្និដ្ឋានរបស់តំណាងមហាអយ្យការថា :

- បណ្តឹងសាទុក្ខរបស់ចុងចម្លើយ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកមកពិចារណា

- សាលដីការដ្ឋប្បវេណីលេខ២៧៤ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យនិងសំរេច ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍.
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ.
- ក្រោយពីបានស្តាប់សារណារបស់លោកម៉ុង ឈាតចម្លើយរបស់លោកឃឹម សន
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ដើម.

**តុលាការកំពូល**

យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៦៤ ចុះថ្ងៃទី៣០-៧-១៩៩៩របស់ឈ្មោះម៉ុង ឈាត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

យល់ឃើញថា ការលើកឡើងរបស់ឈ្មោះម៉ុង ឈាត ក្នុងសារណាចុះថ្ងៃទី០៣-៥-២០០០ ថាគោរបស់ខ្លួនពិតជាបានជាន់ទៅលើជនរងគ្រោះប្រាកដមែន ប៉ុន្តែការដែលគោខ្លួនមុនបង្ករឱ្យមានគ្រោះថ្នាក់លើជនរងគ្រោះ គឺបណ្តាលមកពីជីដូនជនរងគ្រោះដេញគោខ្លួន ទើបគោនោះងាកទៅជាន់លើជនរងគ្រោះដូច្នេះ កំហុសនេះក៏ត្រូវរួមចំណែកពីជីដូនជនរងគ្រោះដែរ ។

ម្យ៉ាងទៀត ជនរងគ្រោះបានព្យាបាល បានជាសះស្បើយរួចហើយដែលចំណាយប្រាក់អស់មួយចំនួន ប៉ុន្តែក្រោយមកជនរងគ្រោះបង្កឱ្យមានគ្រោះថ្នាក់ជាថ្មីដោយកំហុសខ្លួនឯង ហើយព្យាបាលជាថ្មីឡើងវិញ ចំណាយអស់ទឹកប្រាក់ម្តងទៀត ហើយចាប់បង្ខំឱ្យខ្លួនសងសំណងជាច្រើនខ្លួនគ្មានលទ្ធភាពសងទេនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា: ទោះបីជាមានការដេញឬមិនដេញគោនោះក៏ដោយក៏គោនេះជាកម្មសិទ្ធិរបស់ខ្លួន ដែលបានបង្កឱ្យគ្រោះថ្នាក់ ធ្ងន់ធ្ងរទៅលើជនរងគ្រោះពិតប្រាកដ ដែលតាមស្មារតី នៃមាត្រា១២៧នៃក្រឹត្យច្បាប់លេខ៣៨ក្រ.ច គឺម្ចាស់កម្មសិទ្ធិករនៃសត្វ ត្រូវតែទទួលខុសត្រូវ នូវសំណងអន្តរាយដែលកើតឡើងពីសត្វរបស់ខ្លួន ។

យល់ឃើញថា ជនរងគ្រោះពិតជារងរបួសដោយសារគោបុកនិងជាន់បណ្តាលឱ្យបាក់ភ្លៅ ហើយត្រូវព្យាបាលអស់រយៈពេលជាយូរនិងអស់ថវិកាជាច្រើន ដែលគប្បីពិចារណាបញ្ហាសំណងនេះជាការចាំបាច់ដល់ជនរងគ្រោះ ។

យល់ឃើញថា លោកម៉ុង ឈាត បានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខលោកប៉ុន្តែចាត់ទុកជាចំពោះមុខ ។

យល់ឃើញថា សាលដីកាឧទ្ធរណ៍លេខ៤៣០ ចុះថ្ងៃទី១២-៧-៩៩របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំង គតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី ចំពោះមុខលោកឃឹម សាន កំបាំងមុខលោកម៉ុង ឈាត**
**ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១- ទទួលបណ្តឹងសាទុក្ខលេខ២៦៤ ចុះថ្ងៃទី៣០-៧-១៩៩៩របស់ឈ្មោះម៉ុង ឈាត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនិងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ៤៣០ ចុះថ្ងៃទី១២-៧-១៩៩៩របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលឈ្មោះម៉ុង ឈាត បានបង់គឺ :

- ពន្ធចុះបញ្ជីក្តី និងពន្ធប្តឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។
- ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

បង្គាប់ឱ្យឈ្មោះម៉ុង ឈាត បង់ពន្ធសមាមាត្រ មួយភាគរយលើចំនួនប្រាក់ដែលត្រូវសង ។

៤- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២-៩-២០០២ ។